អនុក្រឹត្យលេខ ៣៦ អ.ន.ក្រ.បក
ស្តីពីការបង្កើតឃុំត្រពាំងភ្លាំង
និងឃុំតាកែន ចំណុះស្រុកឈូក ខេត្តកំពត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/ ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករាឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១.- ត្រូវបានបង្កើតឃុំត្រពាំងភ្លាំង និងឃុំតាកែន ចំណុះស្រុកឈូក ខេត្តកំពត ដោយកាត់យកពីភូមិសាស្ត្រ ឃុំល្បើក ស្រុកឈូក ខេត្តកំពត ។

មាត្រា ២.- ឃុំត្រពាំងភ្លាំង និងឃុំតាកែន មានព្រំប្រទល់រដ្ឋបាល ដូចខាងក្រោមៈ

ក- ឃុំត្រពាំងភ្លាំងៈ

-ខាងជើងទល់និងឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

- ខាងត្បូងទល់នឹងឃុំស្ទឹងកែវ ឃុំថ្មី ស្រុកកំពត និងឃុំល្បើក ស្រុកឈូក ខេត្តកំពត ។
- ខាងលិចទល់នឹងអូរបាក់រទេះ ស្រុកកំពង់សីលា ខេត្តកោះកុង ។
- ខាងកើតទល់នឹងឃុំតាកែន ស្រុកឈូក ខេត្តកំពត ។

ខ- ឃុំតាកែន :

- ខាងជើងទល់នឹងឃុំដំបូករូង ឃុំជាំសង្កែ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។
- ខាងត្បូងទល់នឹងល្បើក ស្រុកឈូក ខេត្តកំពត ។

- ខាងលិចទល់នឹងត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ។

- ខាងកើតទល់នឹងឃុំស្រែចែង ឃុំស្វាយអញ្ជើត ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្តកំពត

មាត្រា ៣.- - ទីតាំងរដ្ឋបាលឃុំត្រពាំងភ្លាំង ស្ថិតនៅក្នុងភូមិកោះស្លា ។

- ទីតាំងរដ្ឋបាលឃុំតាកែន ស្ថិតនៅក្នុងភូមិមនោសុខ ។

មាត្រា ៤.- បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងគ្រប់ រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

អនុក្រឹត្យលេខ ៣៧ អ.ន.ក្រ.បក

ស្តីពី

ការបង្កើតឃុំអូរស្វាយ ចំណុះស្រុកសំរោង ខេត្តឧត្តរមានជ័យ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករាឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ